## របៀបអានរបាយការណ៍សិស្ស

លទ្ធផលរបស់សិស្សនីមួយៗត្រូវបានបង្ហាញនៅលើរង្វាស់ខ្នាតសមិទ្ធិផលសំរាប់ការធ្វើតេស្តវាយតម្លៃមុខវិជ្ជានីមួយៗ។

លទ្ធផលនៃការធ្វើតេស្តវាយតម្លៃសមត្ថភាពសិក្សាសំរាប់អក្ខរកម្មនិងលេខនព្វន្តនៃសិស្សថ្នាក់ទី 3, ទី 5, ទី 7 និងទី 9 ត្រូវបានរាយការណ៍តាមរង្វាស់ខ្នាតមួយ ចាប់ពីលំដាប់ក្រុមទី 1 ដល់លំដាប់ក្រុមទី 10 ។ រង្វាស់ខ្នាតនៃសមិទ្ធិផលគឺជាតំណាងកម្រិតជំនាញនិងការយល់ដឹងកាន់តែខ្លាំងឡើង ដែលបង្ហាញឲ្យឃើញនៅក្នុងការធ្វើតេស្តវាយតម្លៃសមត្ថភាពសិក្សាទាំងឡាយ។

ឧទាហរណ៍៖ លទ្ធផលសំរាប់ថ្នាក់ទី 3 ត្រូវបានរាយការណ៍នៅក្នុងលំដាប់ក្រុមទី 1 ដល់លំដាប់ក្រុមទី 6។




អាជ្ញាធរកម្មវិធីសិក្សានិងធ្វើតេស្តវាយតម្លៃសមត្ថភាពសិក្សារដ្ឋវិចតូរិយ៉ាផ្តល់កម្មវិធីសិក្សាមានគុណភាពខ្ពស់ ការធ្វើតេស្តវាយតម្លៃសមត្ថភាពសិក្សា និងការរាយការណ៍ដែលលើកកំពស់ការរៀនសូត្រអស់មួយជីវិតរបស់បុគ្គលនីមួយៗ។

បោះពុម្ពដោយ
Victorian Curriculum and Assessment Authority
41 St Andrews Place
East Melbourne
Victoria 3002 Australia

ទូរស័ព្ទ 1800 648 637
ទូរសារ +61 3 9225 2334

អ៊ីមែល vcaa.naplan.help@edumail.vic.gov.au
វ៉ិបសៃ www.vcaa.vic.edu.au

ដើម្បីទទួលព័ត៌មានបន្ថែមនិងការពិភាក្សាអំពីលទ្ធផលរបស់កូនលោកអ្នក សូមទាក់ទងនាយកសាលារៀនរបស់កូនលោកអ្នក។ លោកអ្នកអាចរកឃើញឯកសារធ្វើតេស្ត NAPLAN នៅតាមវ៉ិបសៃរបស់អាជ្ញាធរកម្មវិធីសិក្សានិងធ្វើតេស្តវាយតម្លៃសមត្ថភាពសិក្សារដ្ឋវិចតូរិយ៉ា។

# កម្មវិធីជាតិធ្វើតេស្តវាយតម្លៃសមត្ថភាពសិក្សា– អក្ខរកម្មនិងលេខនព្វន្ត (NAPLAN) ឆ្នាំ 2009

## ព័ត៌មានអំពីរបាយការណ៍សំរាប់មាតាបិតាសិស្ស

THE NATIONAL ASSESSMENT PROGRAM - LITERACY AND NUMERACY (NAPLAN)
Report Information for Parents - **Khmer**

VICTORIAN CURRICULUM AND ASSESSMENT AUTHORITY

Victoria
The Place To Be

# កម្មវិធីជាតិធ្វើតេស្តវាយតម្លៃសមត្ថភាពសិក្សា - តេស្តអក្ខរកម្មនិងលេខនព្វន្ត (NAPLAN)

នៅខែឧសភា ឆ្នាំ 2009 សិស្សថ្នាក់ទី 3, ទី 5, ទី 7 និងទី 9 ទូទាំងប្រទេសអូស្ត្រាលី បានធ្វើតេស្តជាតិផ្នែកអក្ខរកម្មនិងលេខនព្វន្ត។ សិស្សជាងមួយលាននាក់មកពីសាលារៀន 9000 នៅក្នុងប្រទេស បានចូលរួមក្នុងការធ្វើតេស្តជាតិនេះ។

របាយការណ៍របស់ NAPLAN បង្ហាញនូវលទ្ធផលនៃការសិក្សារបស់សិស្សនីមួយៗ។ របាយការណ៍នេះប្រាប់លោកអ្នកថាតើកូនលោកអ្នកកំពុងទទួលលទ្ធផលយ៉ាងណា បើប្រៀបធៀបនឹង៖

- សិស្សឯទៀតនៅក្នុងប្រទេសអូស្ត្រាលី
- ពិន្ទុមធ្យមទូទាំងប្រទេស ក្នុងការធ្វើតេស្ត NAPLAN និង
- ទំហំនៃសមិទ្ធផលសំរាប់សិស្សធុនកណ្តាល 60% នៅក្នុងប្រទេសអូស្ត្រាលី។

## តើការធ្វើតេស្ត NAPLAN វាយតម្លៃសមត្ថភាពសិក្សាអ្វីខ្លះ?

កិច្ចការធ្វើតេស្តវាយតម្លៃសមត្ថភាពសិក្សាផ្នែកអក្ខរកម្ម វាស់ស្ទង់នូវសមិទ្ធផលរបស់សិស្សក្នុងការអាន  សរសេរ និងក្បួនភាសា។ កិច្ចការធ្វើតេស្តវាយតម្លៃសមត្ថភាពសិក្សាផ្នែកលេខនព្វន្តវាស់ស្ទង់នូវសមិទ្ធផលរបស់សិស្សក្នុងការធ្វើលេខ; ពីជគណិត; មុខងារនិងលំនាំ; រង្វាស់រង្វាល់ ឱកាសនិងទិន្នន័យ; ហើយនិងលំហ។

## គោលបំណងនៃការធ្វើតេស្ត NAPLAN

លទ្ធផល NAPLAN បន្ថែមតម្លៃទៅលើការធ្វើតេស្តវាយតម្លៃសមត្ថភាពសិក្សានិងការរាយការណ៍ដោយគ្រូបង្រៀន តាមរយៈការបង្ហាញសមិទ្ធផលរបស់សិស្ស ដោយប្រៀបធៀបនឹងក្រុមទូលំទូលាយមួយនៃសិស្សទាំងឡាយនៅក្នុងរដ្ឋនិងទូទាំងប្រទេសអូស្ត្រាលី។ ជាការសំខាន់ក្នុងការចងចាំថា លទ្ធផលទាំងឡាយឆ្លុះបញ្ចាំងចំណេះដឹងសិក្សារបស់សិស្ស នៅនឹងពេលតែមួយគត់ប៉ុណ្ណោះ។

គ្រូបង្រៀននៅគ្រប់សាលារៀនទាំងអស់ធ្វើតេស្តវាយតម្លៃសមត្ថភាពសិក្សាក្នុងផ្នែកអក្ខរកម្ម និងលេខនព្វន្តនៃសិស្សរបស់ខ្លួនជាទៀងទាត់។ ការធ្វើតេស្ត NAPLAN គឺជាការបង្គ្រប់បន្ថែម ប៉ុន្តែមិនជំនួសឲ្យព័ត៌មានដែលប្រមូលផ្តុំដោយគ្រូបង្រៀនឡើយ។

## របាយការណ៍ទាំងឡាយ

ទម្រង់នៃរបាយការណ៍ទាំងឡាយមានលក្ខណៈដូចគ្នាសំរាប់រដ្ឋនិងដែនដីទាំងឡាយក្នុងប្រទេសអូស្ត្រាលី ហើយត្រូវបានកំណត់ទូទាំងប្រទេសសំរាប់ការរាយការណ៍ជូនដល់មាតាបិតាសិស្សនូវសមិទ្ធផលរបស់សិស្សសំរាប់ NAPLAN ក្នុងឆ្នាំ 2009។

របាយការណ៍នីមួយៗមានរួមទាំង៖

- ព័ត៌មានរបស់សិស្សនិងសាលារៀន
- ព័ត៌មានអំពីបណ្តាតេស្ត NAPLAN
- ផ្នែកមួយអំពី"របៀបអានរបាយការណ៍របស់សិស្ស"
- លទ្ធផលនៃសមិទ្ធផលរបស់សិស្សនីមួយៗសំរាប់ការអាន សរសេរ និងក្បួនភាសា (ដែលមានការប្រកបអក្សរ វេយ្យាករណ៍ និងវណ្ណយុត្តិ) ព្រមទាំងលេខនព្វន្ត នៅលើរង្វាស់ខ្នាតសមិទ្ធផលរបស់ NAPLAN
- ការចង្អុលបង្ហាញសំរាប់ការធ្វើតេស្តវាយតម្លៃមុខវិជ្ជានីមួយដែលបង្ហាញនូវលទ្ធផលជាតិជាមធ្យម និងលទ្ធផលរបស់សិស្សក្រុមកណ្តាល 60% នៃលទ្ធផលទូទាំងប្រទេស
- សេចក្តីពណ៌នាជាលាយលក្ខណ៍អក្សរសំរាប់ការវាយតម្លៃមុខវិជ្ជានីមួយៗ ដោយប្រាប់ឲ្យដឹងនូវប្រភេទនៃជំនាញទាំងឡាយ ដែលទទួលការធ្វើតេស្តវាយតម្លៃសមត្ថភាពសិក្សា
- តារាងមួយនៃ"សេចក្តីសង្ខេបនៃជំនាញទាំងឡាយដែលទទួលការធ្វើតេស្តវាយតម្លៃសមត្ថភាពសិក្សា" ដែលពណ៌នានូវជំនាញទាំងឡាយ ដែលសិស្សទំនងជាបង្ហាញនៅក្នុងលំដាប់ក្រុមនីមួយៗក្នុងចំណោមលំដាប់ក្រុមទាំងឡាយ។

## ការអានរបាយការណ៍

ចំណុចខ្មៅមួយនៅលើរូបក្រាហ្វិកនីមួយៗតំណាងឲ្យលទ្ធផលរបស់កូនលោកអ្នក។ ជំនាញទាំងពួងពាក់ព័ន្ធនឹងលំដាប់ក្រុមដែលមានចំណុចណាមួយនៅក្នុងនោះ ត្រូវបានពណ៌នានៅទំព័រខាងខ្នងនៃរបាយការណ៍នេះ។ សិស្សដែលទទួលការធ្វើតេស្តវាយតម្លៃសមត្ថភាពសិក្សានៅក្នុងលំដាប់ក្រុមជាក់លាក់ណាមួយ ទំនងជាបានឆ្លើយយ៉ាងត្រឹមត្រូវទៅនឹងសំណួរពាក់ព័ន្ធនឹងជំនាញទាំងឡាយនៅក្នុងលំដាប់ក្រុមនោះ និងនៅក្នុងលំដាប់ក្រុមនីមួយៗដែលនៅពីខាងក្រោម។ លទ្ធផលរបស់កូនលោកអ្នកអាចយកទៅប្រៀបធៀបនឹងលទ្ធផលនៃសិស្សក្រុមកណ្តាល 60% នៃសិស្សអូស្ត្រាលីទាំងអស់ និង/ឬ ប្រៀបធៀបនឹងលទ្ធផលជាតិជាមធ្យម សំរាប់កម្រិតថ្នាក់របស់កូនលោកអ្នក។

## ស្តង់ដារជាតិទាបបំផុត

ស្តង់ដារជាតិទាបបំផុតសំរាប់អក្ខរកម្មនិងលេខនព្វន្ត បានជំនួសឲ្យកម្រិតគំនូសជាតិ។ គំនិតនៃកម្រិតគំនូសចំណុចតែមួយគត់ ត្រូវបានជំនួសដោយសញ្ញាណនៃស្តង់ដារទាបបំផុតមួយដែលកំណត់ដោយលំដាប់ក្រុមជាក់លាក់ណាមួយដូចខាងក្រោមនេះ៖

- សំរាប់ថ្នាក់ទី 3 ស្តង់ដារទាបបំផុតគឺលំដាប់ក្រុមទី 2
- សំរាប់ថ្នាក់ទី 5 ស្តង់ដារទាបបំផុតគឺលំដាប់ក្រុមទី 4
- សំរាប់ថ្នាក់ទី 7 ស្តង់ដារទាបបំផុតគឺលំដាប់ក្រុមទី 5
- សំរាប់ថ្នាក់ទី 9  ស្តង់ដារទាបបំផុតគឺលំដាប់ក្រុមទី 6។

បើចំណុចខ្មៅដែលតំណាងនូវលទ្ធផលរបស់កូនលោកអ្នកស្ថិតនៅក្នុងលំដាប់ក្រុមទាបបំផុតសំរាប់កម្រិតថ្នាក់របស់កូនលោកអ្នក  សមិទ្ធផលរបស់កូនលោកអ្នកសំរាប់តេស្តនេះគឺមានកម្រិតទាបជាងស្តង់ដារទាបបំផុត ហើយលោកអ្នកគួរពិភាក្សាអំពីលទ្ធផលនេះជាមួយសាលារៀនរបស់កូនលោកអ្នក។

## ឧទាហរណ៍ទាំងឡាយនៃរូបក្រាហ្វិករង្វាស់ខ្នាតសមិទ្ធផល NAPLAN




ចំណុចខ្មៅចង្អុលបង្ហាញថា សិស្សថ្នាក់ទី 3 នេះ បានទទួលលទ្ធផលមួយនៅក្នុងលំដាប់ក្រុមទី 4 សំរាប់ការអាន ដែលមានកម្រិតខ្ពស់ជាងលទ្ធផលមធ្យមទូទាំងប្រទេសបន្តិច។ រូបត្រីកោណខ្មៅនេះចង្អុលបង្ហាញនូវលទ្ធផលមធ្យមទូទាំងប្រទេសសំរាប់សិស្សថ្នាក់ទី 3។ ផ្នែកពណ៌ខៀវខ្ចីបង្ហាញនូវទំហំនៃសមិទ្ធផលសំរាប់សិស្សក្រុមកណ្តាល 60% នៃសិស្សថ្នាក់ទី 3 ។




ចំណុចខ្មៅចង្អុលបង្ហាញថា សិស្សថ្នាក់ទី 5 នេះបានសំរេចលទ្ធផលទាបជាងស្តង់ដារជាតិទាបបំផុតសំរាប់ការសរសេរ (ថ្នាក់ទី 5 លំដាប់ក្រុមទី 4)។ មាតាបិតានៃសិស្សដែលទទួលលទ្ធផលដូចនេះ គួរពិភាក្សាជាមួយសាលារៀន។




ចំណុចខ្មៅចង្អុលបង្ហាញថា សិស្សថ្នាក់ទី 7 នេះបានសំរេចលទ្ធផលមួយ ក្នុងលំដាប់ក្រុមទី 9 សំរាប់លេខនព្វន្តដែលមានកម្រិតខ្ពស់ខ្លាំងជាងលទ្ធផលលេខនព្វន្តភាគច្រើន និងលទ្ធផលមធ្យមទូទាំងប្រទេសសំរាប់សិស្សថ្នាក់ទី 7។